# ករណីសិក្សានៅតុលាការកូនកាត់

# ដំណើរការឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅ Timor Leste: កាលពីអតីតកាល[1]

៥ មិនា ២០០៦

ឯកសារនេះស្វែងរកការវិភាគលើដំណើរការឧក្រិដ្ឋកម្មធ្ងន់ធ្ងរ (គណៈកម្មាធិការពិសេស និង អង្គភាពឧក្រិដ្ឋកម្មធ្ងន់ធ្ងរ) ដែលត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិនៅ Timor Leste ដើម្បីជំនុំជម្រះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរនៅឆ្នាំ១៩៩៩ ។ យន្តការនេះបញ្ចប់អាណត្តិរបស់ខ្លួននៅឆ្នាំ២០០៥ ហើយឯកសារនេះមានបំណងវិភាគទូទៅបន្ទាប់ពីការបញ្ចប់ដំណើរការនេះ ។ ឯកសារនេះជាផ្នែកមួយនៃឯកសារច្រើនស៊េរីដែលមានបំណងផ្តល់ព័ត៌មាន និងការវិភាគគោលនយោបាយ និងបញ្ហាអនុវត្តដែលប្រឈមដោយតុលាការ រួមមាន:

- ប្រវត្តិសង្ខេបនៃជម្លោះ និង ចរិតលក្ខណៈនៃអំពើព្រៃផ្សៃនៅ Timor Leste
- ព័ត៌មានសាវតាស្តីពីការបង្កើតគណៈកម្មាធិការពិសេស និង អង្គភាពឧក្រិដ្ឋកម្មធ្ងន់ធ្ងរ
- ការវិភាគលើគណៈកម្មាធិការពិសេស
- ការវិភាគលើអង្គភាពឧក្រិដ្ឋកម្ម
- យុត្តាធិការ និង ក្របខណ្ឌច្បាប់
- សមត្ថភាពការពារក្តី និង បញ្ហាទាក់ទងទៅនឹងយុត្តិធម៌
- បញ្ហាទាក់ទងទៅនឹងប្រសិទ្ធិភាព និងថវិកា
- កម្មវិធីផ្សព្វផ្សាយ និងទស្សនរបស់ពលរដ្ឋ
- កម្មសិទ្ធិករក្នុងស្រុក និង កិច្ចគាំទ្រខាងនយោបាយ
- ទំនាក់ទំនងជាមួយគណៈកម្មាធិការទទួលពាក្យបណ្តឹង ស្វែងរកការពិត និង ការផ្សះផ្សារជាតិ
- កេរ្តិ៍មរតក
- ការបញ្ចប់យុទ្ធសាស្ត្រ និង ដំណើរការឧក្រិដ្ឋកម្មធ្ងន់ធ្ងរនាថ្ងៃអនាគត

[1] ករណីសិក្សានេះតាក់តែងឡើងដោយ Caitlin Reiger បំរើការងារនៅកម្មវិធីឃ្លាំមើលប្រព័ន្ធតុលាការនៅ**ទីម៉ូរ** ពីឆ្នាំ២០០១ ដល់ឆ្នាំ២០០៣ ។បញ្ហាត្រូវបានធ្វើបច្ចុប្បន្នភាពនៅឆ្នាំ២០០៣ ដោយ Maieke Wierda មន្ត្រីជាន់ខ្ពស់របស់មជ្ឈមណ្ឌលយុត្តិធម៌អន្តរកាល (ICTJ) ។ ឯកសារពឹងអាស្រ័យមួយផ្នែកដោយការវិភាគឯកសារមិនទាន់ផ្សព្វផ្សាយដែល Paul Seil ផ្តល់ឲ្យ ICTJ ។ ទូទាំងឯកសារនេះប្រើឈ្មោះ Timor-Leste ជាឈ្មោះប្រទេសផ្លូវការចាប់តាំងពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២ និង ឈ្មោះ East Timor ឈប់ប្រើចាប់ពីថ្ងៃនោះមក ។ ទស្សនសំដែងនៅក្នុងឯកសារជាទស្សនរបស់អ្នកនិពន្ធ មិនជាមែនជាទស្សនរបស់ ICTJ ឡើយ ។

គោលបំណងនៃករណីសិក្សានេះ គឺដើម្បីផ្តល់ព័ត៌មានជាមូលដ្ឋាន ដែលព័ត៌មានមួយចំនួននៅតែមិនអាចរកបាននៅឡើយ ដើម្បីធ្វើជាមគ្គុទេសក៏ដល់អ្នកធ្វើគោលនយោបាយ និងដៃគូរអភិវឌ្ឍន៍ ដើម្បីបង្កើត និងអនុវត្តន៍យន្តការស្រដៀងគ្នា ។ ករណីសក្សាស្រដៀងគ្នាត្រូវបានបង្កើតនៅ**កូសូវ៉ូ** និង **សៀរ៉ាឡេអូន** ។

*សង្ខេបសេចក្តីសន្និដ្ឋាន*

ឧបសគ្គដ៏ចំបងដែលដំណើរការឧក្រិដ្ឋកម្មធ្ងន់ធ្ងរប្រឈម គឺថាជនសង្ស័យភាគច្រើនស្ថិតនៅក្នុងប្រទេសឥណ្ឌូនេស៊ី ហើយរដ្ឋាភិបាល Timor Leste មិនមានលទ្ធភាពចាប់ខ្លួនពួកគេ។ចំណុចនេះបានចោទជាបញ្ហាទាក់ទងទៅនឹង ភាពជោគជ័យនៃដំណើរការទាំងមូល និងភាពសមស្របក្នុងការបង្កើតតុលាការកូនកាត់នៅ Timor Leste ។ គេពុំមានក្តីសង្ឃឹមថាអង្គភាពឧក្រិដ្ឋកម្មធ្ងន់ធ្ងរអាចចាប់ជនសង្ស័យទាំងនោះបាន ដោយពិចារណាលើភាពស្ទាក់ស្ទើររបស់សហគមន៍អន្តរជាតិក្នុងការដាក់ការគាបសង្កត់ទៅលើប្រទេសឥណ្ឌូនេស៊ី ។ទិដ្ឋភាពនេះត្រូវបានមើលឃើញដោយអ្នកអង្កេតការភាគច្រើនចាប់តាំងពីដំណាក់កាលដំបូងមកម្លេះ ហើយវាស្ថិតនៅក្នុងចំណោមមូលហេតុចំបងដែលនាំឲ្យមានកិច្ចគាំទ្រដល់សេចក្តីអំពាវនាវសុំបង្កើតតុលាការអន្តរជាតិមួយ រួមមានគណៈកម្មាធិការស៊ើបអង្កេតអន្តរជាតិដែលបង្កើតឡើងដោយស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាតិទទួលបន្ទុកសិទ្ធិមនុស្ស ។ជាចុងក្រោយ គណៈកម្មាធិការពិសេសតម្រូវឲ្យមានការផ្តល់អំណាចក្រោមជំពូក VII ពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ប៉ុន្តែ ពុំមានការជួយគាំទ្រផ្នែកនយោបាយជាអន្តរជាតិឲ្យបានគ្រប់គ្រាន់[2]ទេ។

នៅមានសេចក្តីសន្និដ្ឋានមួយចំនួនទៀទាក់ទងនឹងដំណើរការឧក្រិដ្ឋកម្មធ្ងន់ធ្ងរ:

- *និត្យានុកូលភាព:* វិបត្តិទាក់ទងទៅនឹងភាពជឿទុកចិត្ត កើតឡើងតាំងពីដំណាក់កាលចាប់ផ្តើមនៃដំណើរការឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលបណ្តាលឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់នីត្យានុកូលភាពរបស់ស្ថាប័ននេះ ។ គេតែងតែដឹងឮថា គណៈកម្មាធិការផ្តន្ទាទោសតែជនជាជាតិ Timor-Leste ប៉ុន្តែមិនបានកាត់ទោសជនជាតិ

[2] អំណាចក្រោមជំពូក VII យោងទៅលើធម្មនុញ្ញរបស់អង្គការសហប្រជាជាតិដែលអនុញ្ញាតឲ្យក្រុមប្រឹក្សាសន្តិសុខ ចាត់វិធានការដើម្បីថែរក្សា ឬ ស្តារសន្តិភាពឡើងវិញ ។

ឥណ្ឌូនេស៊ីទេ[3] ។ ស្ថានការណ៍បែបនេះកាន់តែអាក្រក់ថែមទៀត បង្កឡើងដោយសវនាការប្រកបដោយគុណវិបត្តិប្រព្រឹត្តទៅនៅ Jakarta កាលពីឆ្នាំ២០០២ និង២០០៣ ពាក់ព័ន្ធជាមួយអំពើហឹង្សាដែលកើតឡើងកាលពីឆ្នាំ១៩៩៩ ។ សាក្សីជនជាតិ Timor-Leste ដែលទទួលរងនូវការគំរាមកំហែងបានចងសម្ព័ន្ធភាពជាមួយលទ្ធផលនៃសវនាការដែលជាទូទៅមានលក្ខណៈប្រមាណមើលងាយ បានលាតត្រដាងតិចតួចអំពីឧក្រិដ្ឋធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តនៅក្នុងប្រទេសរបស់ខ្លួន ។ ស្ថានភាពបែបនេះបានបង្កឲ្យមានការយល់ផ្ទុយពីសំណាក់អ្នកដឹកនាំនយោបាយ ដែលចង់បានទំនាក់ទំនងល្អជាមួយឥណ្ឌូនេស៊ី ។ ទោះបីជាដំណើរការឧក្រិដ្ឋកម្មធ្ងន់ធ្ងរទទួលបានការគាំទ្រផ្នែកនយោបាយ ឬ ធនធានពីអង្គការសហប្រជាជាតិដែលខ្លួនត្រូវការ ដើម្បីបំពេញបេសកម្មឲ្យបានជោគជ័យក៏ដោយ ហើយការបែងចែកធនធានត្រូវបានកែលំអរនៅដំណាក់កាលចុងក្រោយនៃដំណើរការក៏ពិតមែន ប៉ុន្តែនៅមានបញ្ហាមួយចំនួនមិនត្រូវបានកែតម្រូវទាំងស្រុងនោះទេ ។

- *យុត្តិធម៌:* ការព្រួយបារម្ភមួយក្នុងចំណោមការព្រួយបារម្ភជាច្រើនទាក់ទងទៅនឹងការអនុវត្តភារកិច្ចគឺពឹងផ្អែកលើគុណភាពរបស់មេធាវីការពារក្តីដែលចាត់តាំងឲ្យជនជាប់ចោទ ។ មានករណីជាច្រើននៅ Timor-Leste ដែលគុណភាពការពារក្តីមានការខ្វះខាត ដែលបង្កឲ្យមានមន្ទិលសង្ស័យទៅលើភាពជឿទុកចិត្តលើដំណើរការទាំងមូល[4] ។ដោយយល់ឃើញថា វិបត្តិនីត្យានុកូលភាពរបស់ដំណើរការឧក្រិដ្ឋកម្មធ្ងន់ធ្ងរបានកើតឡើងរួចមកហើយ ហេតុដូច្នេះ មានទស្សនៈថាការកាត់ទោសគឺគ្រាន់តែ Fait accompli តិចឬច្រើននៅក្នុងករណីសឹងតែទាំងអស់ តែប៉ុណ្ណោះ ដោយសារការកង្វះខាតការការពារក្តីឲ្យបានត្រឹមត្រូវ ។បន្ទាប់ពីមានការបង្កើតអង្គភាពមេធាវីការពារក្តី ការផ្តល់សេវាការពារត្រូវបានកែលំអ ។ទោះជាបែបនេះក្តី បញ្ហានៅតែកើតមានដដែល ដោយសារតែមេធាវីការពារក្តីភាគច្រើនពុំមានបទពិសោធន៍ការពារឧក្រិដ្ឋកម្មធ្ងន់ធ្ងរបែបនេះ ។

---

[3] សូមមើលលិខិតរបស់តំណាងជនរងគ្រោះ Timor-Leste និង អង្គការក្រៅរដ្ឋាភិបាលផ្ញើរទៅលោក កូ ហ្វីអាណាន់ ចុះនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៤ ស្នើសុំលោក អគ្គលេខាធិការតែងតាំងអ្នកជំនាញការដើម្បីពិនិត្យបញ្ហាការទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌ(នៅក្នុងសំណុំរឿងរបស់ ICTJ) ។

[4] "អ្វីដែលធ្វើឲ្យភ័យខ្លាច គឺថាបន្ទាប់ពីបញ្ចប់ដំណើរឧក្រិដ្ឋកម្មធ្ងន់ធ្ងរនេះ ប្រជាជននឹងនិយាយថាពុំមានយុត្តិធម៌ទេ ដោយសារពួកគេមិនទទួលបានមេធាវីការពារក្តីមានគុណភាពល្អ ឬ ពួកគេមិនទទួលបានអ្នកប្រែភាសាប្រកបដោយគុណភាព ។ នេះគឺជាអ្វីដែលធ្វើឲ្យភ័យខ្លាចថានឹងកើតឡើង" សំដីរបស់លោក Siri Frigaard, អគ្គព្រះរាជអាជ្ញារងសម្រាប់ដំណើរការឧក្រិដ្ឋកម្មធ្ងន់ធ្ងរ (DGPSC) ។ ដកស្រង់ចេញពីគេហទំព័រ: www.etan.org/et2002b/june/23-30/28specal.htm.

- *ផែនការ:* ការជ្រើសរើសបុគ្គលិកឲ្យបានគ្រប់គ្រាន់បានក្លាយជាបញ្ហាប្រឈមរបស់ដំណើរការឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅទូទាំងដំណើរការនីតិវិធីរបស់ខ្លួន ។ នៅដំណាក់កាលខុសៗគ្នានៃកិច្ចប្រតិបត្តិការ គណៈកម្មាធិការ និង អង្គភាពឧក្រិដ្ឋកម្មធ្ងន់ធ្ងរបានជួបប្រទេះនូវវិបត្តិជាច្រើនដែលហាក់ដូចជាការបង្កឡើងដោយជីវិតវដ្តនៃបេសកម្មរបស់អង្គការសហប្រជាជាតិ វិសាលភាពនៃប្រតិបត្តិការ ជាពិសេសអង្គភាពឧក្រិដ្ឋកម្មធ្ងន់ធ្ងរបានកាត់បន្ថយកិច្ចប្រតិបត្តិការគួរឲ្យកត់សំគាល់ ។ជាលទ្ធផល កិច្ចខិតខំប្រឹងជាច្រើនដែលធ្វើឡើងដោយបុគ្គលិកជាន់ខ្ពស់នៃអង្គភាពឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ព្រមទាំងអង្គការអន្តរជាតិមួយចំនួនដែលមានចិត្តភក្រក្តីជាមួយអង្គភាពនេះ បានបញ្ចុះបញ្ចូលឲ្យមានការបន្តកិច្ចសន្យាការងាររបស់បុគ្គលិកដែលមានស្រាប់ ប្រសិនបើគ្មានការជ្រើសរើសបន្ថែម ។ ទោះបីជាមានមន្ទិលសង្ស័យលើការប្តេជ្ញាចិត្តរបស់អង្គការសហប្រជាជាតិ និងរដ្ឋាភិបាល ក៏មិនបានបង្កើតនូវបរិយាកាសដែលធ្វើឲ្យចុះថយនូវទឹកចិត្តរបស់បុគ្គលិកដែរ ។ ប៉ុន្តែ បរិយាកាសបែបនេះនៅតែជំរុញឲ្យបេក្ខជនឆ្នើមស្វែងរកការងារជាមួយគណៈកម្មាធិការ ឬ អង្គភាពឧក្រិដ្ឋកម្មធ្ងន់ធ្ងរដដែល ។ជាចុងក្រោយ សេចក្តីសម្រេចដើម្បីពន្លឿនដំណើរឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ត្រូវបានជំរុញដោយការពន្លឿនបេសកម្មទៅវិញ ជាជាងសេចក្តីត្រូវការនៃដំណើរការព្រហ្មទណ្ឌទៅវិញ ហេតុដូច្នេះ មានបញ្ហាជាច្រើនមិនបានដោះស្រាយ ។
- *ផលប៉ះពាល់:* អត្ថប្រយោជន៏ចំពោះសំណើម៉ូដែលទីម័រ គឺការនៅជិតជាមួយជនរងគ្រោះ ដែលជាគោលការណ៍ ការស្វែងរកយុត្តិធម៏មានអត្ថន័យច្រើន មិនសម្រាប់សាក្សីប៉ុន្មាននាក់ទេ តែសម្រាប់ប្រទេសទាំងមូល ។ វាត្រូវបានទទួលស្គាល់ជាទូទៅថា ដើម្បីបំរើផលប្រយោជន៏ខាងយុត្តិធម៏ ហើយជាពិសេសផលប្រយោជន៏របស់ជនរងគ្រោះ ប្រសិនអាចធ្វើបាន សវនាការត្រូវតែប្រព្រឹត្តទៅនៅក្នុងប្រទេសដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត ។ ប៉ុន្តែ ហានិភ័យជាប់ពាក់ព័ន្ធជាមួយការបរាជ័យ ជាពិសេសក្នុងបរិបទដែលផលប្រយោជន៏របស់ជនរងគ្រោះត្រូវបានលើកកំពស់ សវនាការនៅក្នុងប្រទេសមានអត្ថន័យជាងសវនការនៅក្រៅប្រទេស ។ ការបរាជ័យទូទៅរបស់ដំណើរការដើម្បីបង្កើតការទទួលខុសត្រូវរបស់បុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត ដែលកំពុងរស់នៅប្រទេសឥណ្ឌូនេស៊ី មានន័យថាការស្វែងរកយុត្តិធម៏នៅថ្នាក់ជាតិ អាចបរាជ័យ និង បង្កើតបានជានិទណ្ឌភាព ។
- *ប្រសិទ្ធិភាពទូទៅ:* ដំណើរការឧក្រិដ្ឋកម្មធ្ងន់ធ្ងរអាចចាត់ទុកថាសម្រេចបានជ័យជំនេះនៅផ្នែកមួយជាពិសេស ការស៊ើបអង្កេត និងការជំម្រះក្តីប្រព្រឹត្តទៅបានឆាប់រហ័ស ។ ក្នុងរយៈបួនឆ្នាំនៃកិច្ចដំណើររបស់ខ្លួន ដំណើរការឧិដ្ឋកម្មធ្ងន់ធ្ងរបានចោទប្រកាន់មនុស្ស៤០០នាក់ បានដំណើរការសវនាការ៣៥ដង និងបានកាត់ទោសជនជាប់ចោទ ៨៤នាក់ និងលើកលែងការចោទប្រកាន់ ២នាក់ ។ អត្រានេះអាច

ប្រៀបធៀបបានជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតអតីតយូហ្គោស្លាវី (ICTY) ដែលក្នុងរយៈពេលជាង ១០ឆ្នាំ តុលាការនេះបានធ្វើការចោទប្រកាន់មនុស្ស ១៣០ ហើយជនជាប់ចោទប្រមាណ ៧០នាក់ត្រូវបានជម្រះ ។ ប៉ុន្តែ ការប្រៀបធៀបបែបមិនបានពិចារណាលើការប្រឈមឡើយ ។ វិសាលភាពរបស់បញ្ហាដែលប្រឈមជាមួយការស៊ើបអង្កេត និង ការកាត់ជម្រះក្តីនៅ ICTY មានទំហំធំជាងឆ្ងាយណាស់ បើធៀបជាមួយបញ្ហាប្រឈមដូចគ្នានេះនៅអង្គភាពឧក្រិដ្ឋកម្មធ្ងន់ធ្ងរវិញ ។ ខណៈ ICTY មានរយៈពេលប្រាំឆ្នាំចុងក្រោយផ្តោតលើការចោទប្រកាន់ប្រឆាំងនឹងបុគ្គលដែលទទួលខុសត្រូវក្នុងកំរិតជាក់លាក់ តែអង្គភាពឧក្រិដ្ឋកម្មធ្ងន់ធ្ងរមិនមានលទ្ធភាពធ្វើបែបនេះបានឡើយ[5] ។ អ្នកទទួលខុសត្រូវខ្ពស់បំផុតមិនអាចចាប់ខ្លួន ហើយកំពុងរស់នៅឥណ្ឌូនេស៊ី ។ ស្ថានភាពបែបនេះ មិនត្រឹមតែជាប់ពាក់ព័ន្ធជាមួយការវាយតំលៃពីប្រសិទ្ធិទូទៅនៃដំណើរការកាត់សេចក្តីទេ ថែមទាំងការវាយតំលៃអំពីភាពស្មុគស្រាញ និងពេលវេលានៃការស៊ើបអង្កេតទៀតផង ។

ករណី Timor-Leste មានភាពភ្លឺច្បាស់ បើពិចារណាលើធនធាន និង ឆន្ទៈនយោបាយក្នុងការស្វែងរកយុត្តិធម៌ក្នុងស្ថានភាពជនជាប់ចោទឆ្លងដែន ។ មានករណីជាច្រើនដែលដំណើរការឧក្រិដ្ឋកម្មនៅមានចំណុចខ្សោយ ។ គេត្រូវវិធានការបន្ថែមជាច្រើន ដើម្បីស្ថាបនាឡើងវិញនូវប្រព័ន្ធតុលាការរបស់ Timor-Leste នៅកំរិតជាតិ ហើយដំណើរការឧក្រិដ្ឋកម្មធ្ងន់ធ្ងរបានបញ្ចប់ការងាររបស់ខ្លួន ដោយបន្សល់ទុកនូវកេរ្តិ៍មរតកតិចតួច ។ ស្របពេលជាមួយគ្នានេះ បញ្ហាដែលថាដំណើរការឧក្រិដ្ឋកម្មធ្ងន់ធ្ងរមានលទ្ធភាពបង្កើតបាននូវវិធានយុត្តិធម៌ដល់ជនរងគ្រោះជាកលាក់ក៏ពិតមែន គេមិនត្រូវមិនអើពើចំពោះសមិទ្ធិផលនេះដែរ ។

---

[5] សូមកត់សំគាល់ថាការជំនុំជម្រះសម្រេចបានជ័យជំនះទៅលើអតីតអនុប្រធានាធិបតីនៃសាធារណរដ្ឋ Repuplika Srpska, លោក Biljana Plasvic ហើយជាងនេះទៅទៀត អតីតប្រធានាធិបតីលោក Slobodan Milosevic ក៏ត្រូវបានចោទប្រកាន់ដោយសារជាប់ពាក់ព័ន្ធជាមួយកូសូវ៉ូ ប៊ូស្នៀ និង ក្រូអាត ។